## ខ្លឹមសារសង្ខេបអត្ថបទ

## បើមិនមាន...ក៏មិនមានដែរ (“ but for” test)

John L. Diamond and et al., Understanding Torts, 5th ed., 2013, pp.179-188

១. ការទទួលខុសត្រូវលើអំពើអនីត្យានុកូល ទាមទារនូវភស្តុតាងបង្ហាញពីកំហុសរបស់ចុងចម្លើយ។ ដើមចោទ ត្រូវបានបង្ហាញ លើសពី៥០ភាគរយ (more likely than not) ទង្វើរបស់ចុងចម្លើយ នាំឱ្យមានការខូចខាត (but for causes) ដល់ដើមចោទ។ ស្តង់ដានេះ សំដៅថាបើមិនមានសកម្មភាពរបស់ចុងចម្លើយ ក៏ការខូចខាតរបស់ដើមចោទមិនកើតមានដែរ។ ទោះបីជាយ៉ាងនេះក្តី លទ្ធផលដូចគ្នាក៏អាចកើតមាន ទោះបីគ្មានឬមានសកម្មភាពរបស់ចុងចម្លើយ។ នេះដូចជាក្នុងករណី បុគ្គលម្នាក់របួសធ្ងន់ ដែលនឹងស្លាប់ជៀសមិនរួច ទោះបីមានឬគ្មានការព្យាបាលខុសបច្ចេកទេសក្តី ក៏នៅតែស្លាប់ដដែល។ នេះអាចបណ្តាលមកពីមូលហេតុបង្កមានច្រើន (multiple causes)។

២. ពាក្យ “but for” សំដៅថា បើមិនមានទង្វើរបស់ចុងចម្លើយ ក៏មិនមានការខូចខាតដល់ដើមចោទដែរ។ ទោះបីជាយ៉ាងនេះក្តី ស្តង់ដានេះ ពិបាកអនុវត្តក្នុងករណីដែលមានចុងចម្លើយច្រើនរូប។ ជាការឆ្លើយតបស្តង់ដាថ្មីមួយទៀត ត្រូវបានបង្កើតឡើង នោះគឺកត្តាជះឥទ្ធិពលច្រើនជាង (substantial factors)។ នេះវាសមស្រប ក្នុងអំពើអនីត្យានុកូល ពាក់ព័ន្ធនឹងការបំពុលបរិស្ថាន ដែលមានអ្នកចូលរួមបំពុលច្រើនគ្នា និងមិនអាចកំណត់ថាអ្នកពាក់ព័ន្ធមួយណា ជាអ្នកបង្ក ឬបង្កខូចខាតច្រើនជាងគេ (materially contributed to injury)។ ម្យ៉ាងទៀត តុលាការនឹងពិចារណាថា ទង្វើរបស់អ្នកបង្កណាមួយនៅកៀក (proximate) នាំទៅឱ្យមានការខូចខាតដល់ដើមចោទ។

៣. ស្តង់ដា But for សម្រាប់បង្ហាញនូវចំណងហេតុនិងផល (causation)។ សំណួរ ត្រូវបានសួរថា តើអ្នកណាជាអ្នកមានបន្ទុកភស្តុតាង?។ ជាទូទៅ ដើមចោទជាអ្នកមានបន្ទុកដាក់ភស្តុតាង។ ក្នុងករណីមានចុងចម្លើយមានច្រើននាក់ តែមិនអាចបង្ហាញថា សកម្មភាពរបស់នរណាមួយ នាំឱ្យមានការខូចខាត បុគ្គលណាមួយក៏អាចទទួលខុសត្រូវ ដោយសារ ទាំងអស់សុទ្ធតែមានកំហុស។ ដើម្បីដោះស្រាយរឿងនេះ តុលាការបានផ្ទេរបន្ទុកផ្តល់ភស្តុតាង ដល់ចុងចម្លើយ បង្ហាញថា គាត់មិនមែនជាអ្នកបង្កនូវការរងគ្រោះ។ ក្នុងន័យនេះ ដើមចោទ

បង្ហាញភស្តុតាង ថាមានការបំពាននូវកាតព្វកិច្ច ហើយចុងចម្លើយ បង្ហាញអំពីចំណងហេតុនិងផល។ គេក៏អាចប្រើទិន្នន័យជាចំនួន (statistic evidence of causation) ដើម្បីបង្ហាញនូវចំណងហេតុនិងផលផងដែរ។

**៤.** ជាចុងក្រោយស្តង់ដាមួយទៀត ត្រូវបានបង្កើតគឺ share market liability អនុវត្តជាពិសេសសម្រាប់ផលិតផលមានវិការៈ ដាក់លក់លើទីផ្សារដែលបង្កខូចខាតដល់អ្នកប្រើប្រាស់។ ដើមចោទ មិនអាចបង្ហាញថាជាកំហុសរបស់អ្នកណាជាក់លាក់ទេ។ ចុងចម្លើយ ជាអ្នកបង្ហាញថាមិនមែនជាអ្នកបង្ក។ ក្នុងករណីមិនអាចទេ គេនឹងអនុលោមទៅតាមចំនួនផលិតផលដាក់លក់លើទីផ្សារ (15 percent of market) សម្រាប់សងការខូចខាត។ តុលាការខ្លះ ទាមទារឱ្យអ្នកចូលរួមបង្ក សងរួមគ្នាដោយសារ បង្កើតហានិភ័យរួមគ្នា (overall risk produced)។ បន្ថែមពីលើនេះ គោលការណ៍សមាមាត្រ ក្នុងការចែកនូវសំណងរវាងអ្នកបង្កត្រូវបានពិចារណាផងដែរ។ ការតម្រូវឱ្យទទួលខុសត្រូវ ស្របទៅនឹងនិន្នាការ ការទទួលខុសត្រូវផ្នែកសង្គម (social responsibility)។

**៥.** ក្នុងវិស័យសុខាភិបាល (ពេទ្យ) វាមានភាពមិនច្បាស់លាស់។ ដូចនេះក្នុងករណីខាងលើ ដែលមានមូលហេតុបង្កជាច្រើន ហើយទោះបីមានសកម្មភាពណាមួយ ឬមិនមាន ក៏មានលទ្ធផលដូចគ្នា (ការខូចខាត) នៅតែមាន។ ការបន្ថយឱកាសក្នុងការបន្តរស់ ឬបាត់ឱកាសក្នុងការបន្តរស់ នឹងត្រូវបានពិចារណា ដើម្បីបង្កើតឱ្យមានការទទួលខុសត្រូវលើអំពើអនីត្យានុកូល។

**ខ្លឹមសារដកស្រង់៖** ដើម្បីឱ្យចុងចម្លើយទទួលខុសត្រូវ ដើមចោទត្រូវបង្ហាញថាបើមិនមានអំពើ ឬសកម្មភាពរបស់ចុងចម្លើយ ការខូចខាតលើដើមចោទក៏មិនកើតមានដែរ។

**ពាក្យគន្លឹះ៖** ចំណងហេតុនិងផល, កម្រិត និងបន្ទុកភស្តុតាង។